មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

អំណត់ត្រាសង្ខេប

ខែមីនា ឆ្នាំ២០១៤

"ឯណាទៅយុត្តិធម៌ខ្ញុំ?"

ខ្លឹមសារសង្ខេប

បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានប្រព្រឹត្តិទៅនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ ប្រជាពលរដ្ឋកម្ពុជាបានអនុវត្តនូវសិទ្ធិសេរីភាពខាងការជួបប្រជុំក្នុងស្ថានភាពមួយដែលពុំធ្លាប់មានពីមុនមក។ ប៉ុន្តែ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ កងកម្លាំងរក្សាសន្តិសុខបានប្រើប្រាស់វិធីសាស្ត្រចាស់របស់ខ្លួន ហើយបានប្រើកម្លាំងហួសហេតុម្តងហើយម្តងទៀតដើម្បីបង្ក្រាបទៅលើអ្នកតវ៉ា។ អំពើហិង្សាក្រោយការបោះឆ្នោត បានបណ្តាលឲ្យមានមនុស្ស៦នាក់ស្លាប់ យ៉ាងហោចណាស់មនុស្សម្នាក់បានបាត់ខ្លួន និងមនុស្សរាប់សិបនាក់ទៀតរងរបួស។ ប៉ុន្តែ ខណៈដែលអ្នកតវ៉ាបានត្រូវអាជ្ញាធរចាប់ខ្លួន ព្រមទាំងប្រឈមនឹងការចោទប្រកាន់នាពេលបច្ចុប្បន្ននេះ គេពុំទាន់ឃើញចំណាត់ការឲ្យមានការស៊ើបអង្កេតឯករាជ្យមួយទៅលើករណីប្រើប្រាស់កម្លាំងរបស់កងកម្លាំងសន្តិសុខកម្ពុជានៅឡើយទេ។

ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះ ពិព័ណ៌នាការប្រើកម្លាំងដ៏លើសលុបពីសំណាក់កងកម្លាំងប្រដាប់អាវុធ និងករណីពាក់ព័ន្ធទៅនឹងការរំលោភបំពានសិទ្ធិមនុស្សទាំងមូលនៅក្នុងអំឡុងពេលក្រោយការបោះឆ្នោត។ ផ្នែកទីពីរ គូសបញ្ជាក់សង្ខេបពីកាតព្វកិច្ចផ្នែកច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្នុងការការពារសិទ្ធិទទួលបានការពិត យុត្តិធម៌ និងដំណោះស្រាយសម្រាប់ជនរងគ្រោះជុំវិញករណីហិង្សាពីសំណាក់កងកម្លាំងប្រដាប់អាវុធ ចំណែកផ្នែកទីបី លើកឡើងពីចំណុចដែលរដ្ឋាភិបាលខកខានពុំបានប្រតិបត្តិតាមកាតព្វកិច្ចទាំងនេះ។ សេចក្តីសន្និដ្ឋានគូសបញ្ជាក់ពីអនុសាសន៍នានារបស់ ម.ស.ម.ក ដាក់ជូនទៅរដ្ឋាភិបាលដើម្បីនាំយកជនល្មើសមកផ្តន្ទាទោស និងដើម្បីបញ្ចប់វដ្តនៃនិទណ្ឌភាព។ អនុសាសន៍របស់ ម.ស.ម.ក ផ្តល់ជូនរដ្ឋាភិបាលមានដូចខាងក្រោមនេះ ៖

- ធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយហ្មត់ចត់ និងប្រកបដោយប្រសិទ្ធភាពតាមរយៈស្ថាប័នឯករាជ្យ និងអព្យាក្រឹត្យនូវរាល់ករណីប្រើកម្លាំងលើសលុប និងការប្រើអាវុធពីសំណាក់មន្ត្រីអនុវត្តច្បាប់
- ចេញផ្សាយនូវរាល់លទ្ធផលនៃការស៊ើបអង្កេតទាំងអស់ដល់សាធារណៈជនទូទៅ ជាពិសេស ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់
- នាំជនទាំងឡាយណាដែលកំណត់ថាជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សមកផ្តន្ទាទោសនៅចំពោះមុខសាលាដម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង, និង

- ធានាដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយ និងសិទ្ធិទទួលបានសំណងត្រឹមត្រូវ។

កំណត់ត្រាសង្ខេបនេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។ ចំពោះគោលបំណងនៃកំណត់ត្រាសង្ខេបនេះ ម.ស.ម.ក បានសម្រេចផ្តោតសំខាន់តែលើព្រឹត្តិការណ៍នានាដែលបង្ហាញពីកម្រិតអំពើហិង្សាធ្ងន់ធ្ងរបំផុតក្នុងអំឡុងពេលក្រោយការបោះឆ្នោត។ កំណត់ត្រាសង្ខេបនេះ មិនរាប់បញ្ចូលរាល់ករណីនៃការប្រើប្រាស់កម្លាំងលើសលុបពីសំណាក់កងកម្លាំងសន្តិសុខរដ្ឋទាំងអស់ ដែលកើតមានក្រោយការបោះឆ្នោតនោះទេ។

ការប្រើកម្លាំងលើសលុប និង ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបន្ទាប់ពីការបោះឆ្នោត

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ខណៈដែលអំពើហិង្សាពាក់ព័ន្ធនឹងការបោះឆ្នោតមានការថយចុះជាងឆ្នាំមុនៗមុនពេលបោះឆ្នោត គេក៏សង្កេតឃើញមានការតឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ហើយសមត្ថភាពប្រកួតប្រជែងពុំស្មើភាពគ្នាក្នុងការធ្វើយុទ្ធនាការរវាងគណបក្សសង្គ្រោះជាតិ (“គ.ស.ជ”) និងគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច (“ប្រ.ជ”)[1]ផងដែរ។ បើទោះបីជា គ.ស.ជ បានទទួលអាសនៈនៅក្នុងរដ្ឋសភាច្រើនជាងចំនួនដែលពុំធ្លាប់ទទួលបានពីមុនមក គឺចំនួន ៥៥ ក្នុងចំណោម១២៣ អាសនៈ[2] ក្នុងរដ្ឋសភានោះក្តី ក៏មានការចោទប្រកាន់ធ្ងន់ធ្ងរជុំវិញករណីបន្លំសន្លឹកឆ្នោត និងភាពមិនប្រក្រតីផ្សេងៗ ក្នុងការបោះឆ្នោត ដែលនាំឲ្យមានការស្នើសុំបង្កើតគណៈកម្មការស៊ើបអង្កេតការបោះឆ្នោតឯករាជ្យមួយ[3]ហើយជាលទ្ធផលនាំឲ្យសមាជិកជាប់ឆ្នោតរបស់ គ.ស.ជ ធ្វើពហិការមិនចូលប្រជុំសភា។ មានតែ ប្រ.ជ ប៉ុណ្ណោះដែលចូលទៅប្រជុំនៅក្នុងរដ្ឋសភា ។

មហាបាតុកម្មត្រូវបានចាប់ផ្តើមឡើងក្នុងខែសីហា ឆ្នាំ២០១៣ ខណៈដែលអ្នកគាំទ្ររបស់ គ.ស.ជ បានប្រឆាំងចំពោះលទ្ធផលបោះឆ្នោតដែលអះអាងថាមានការលួចបន្លំលទ្ធផលបោះឆ្នោត។ នៅចុងឆ្នាំ២០១៣ ការតវ៉ានានាបានធ្វើឡើងកាន់តែញឹកញាប់ ខណៈដែលកម្មករកាត់ដេរបានធ្វើបាតុកម្មទាមទារឲ្យមានលក្ខខណ្ឌការងារល្អប្រសើរ និងដំឡើងប្រាក់ខែ ហើយសកម្មជនដីធ្លីបានធ្វើបាតុកម្មដើម្បីទាមទារឲ្យមានការគោរពសិទ្ធិដីធ្លីរបស់ពួកគេ។

អំឡុងពេល២ ឬ៣ សប្តាហ៍ដំបូងនៃការតវ៉ារបស់គណបក្សប្រឆាំង បានជួបនឹងភាពអត់ធ្មត់ដ៏កម្រ និងមិនគួរឲ្យនឹកស្មានដល់ពីសំណាក់អាជ្ញាធរ តែមិនយូរប៉ុន្មាន សេរីភាពខាងការជួបប្រជុំបានប្រឈមនឹងគ្រោះថ្នាក់

---

[1] ម.ស.ម.ក “ក្រសួងព័ត៌មានហាមស្ថានីយវិទ្យុទាំងអស់ក្នុងការផ្សព្វផ្សាយកម្មវិធីវិទ្យុបរទេសក្នុងអំឡុងយុទ្ធនាការបោះឆ្នោត” (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/1e0u5Xy។

[2] នៅ វ៉ាស៊ីនតោន និង ស៊ីម៉ុន លីស “ អាមេរិកស្នើឲ្យធ្វើការស៊ើបអង្កេតទៅក្នុងភាពមិនប្រក្រតីនៃការបោះឆ្នោត (*ខេម ប៊ូឆាដេលី*) (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/1e0y83d។

[3] អង្គការឃ្លាំមើលសិទ្ធិមនុស្ស “ចាំបាច់ត្រូវធ្វើការស៊ើបអង្កេតទៅក្នុងការបោះឆ្នោតដោយឯករាជ្យ” (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/Kk3CcT។

ដោយហេតុថា កងកម្លាំងប្រដាប់អាវុធបានសម្រេចប្រើប្រាស់មធ្យោបាយចាស់របស់ពួកគេវិញ។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ ការប៉ះទង្គិចនានា បានផ្ទុះឡើងនៅក្នុងរាជធានីភ្នំពេញ រវាងកងកម្លាំងប្រដាប់អាវុធ និងបាតុករដែលបានចូលរួមក្នុងបាតុកម្មរបស់ គ.ស.ជ។ នៅពេលនោះមានអ្នកគាំទ្ររបស់ គ.ស.ជ ជាច្រើន ប្រមាណ ៣០.០០០នាក់ បានប្រមូលផ្តុំគ្នានៅលើទីលានប្រជាធិបតេយ្យ ដើម្បីសម្តែងនូវការមិនពេញចិត្តរបស់ខ្លួនចំពោះលទ្ធផលបោះឆ្នោត។ បាតុករមួយចំនួន បានចេញពីទីលានប្រជាធិបតេយ្យ ដោយមានបំណងហែក្បួនដោយពុំមានការគ្រោងទុកនៅទូទាំងរាជធានីភ្នំពេញ។ ប៉ុន្តែ ក្រោយមក បាតុករទាំងនោះត្រូវបានកងកម្លាំងរក្សាសន្តិសុខបំបែកទៅវិញដោយ។ បន្ទាប់ពីការប្រឈមមុខដាក់គ្នារយៈពេលយូរជាមួយកងកម្លាំងប្រដាប់អាវុធ អំពើហិង្សាមួយបានផ្ទុះឡើងនៅម្តុំវិថីព្រះស៊ីសុវត្ថិ រវាងយុវជនរាប់សិបនាក់ដែលចោលដុំថ្ម ជាមួយកងរាជអាវុធហត្ថ និងប៉ូលីសបង្ក្រាបកុប្បកម្មជាច្រើនរយនាក់ប្រដាប់ដោយកាំភ្លើងបាញ់គ្រាប់ពិត កាំភ្លើងបាញ់គ្រាប់ជំរ ឧស្ម័នបង្ហូរទឹកភ្នែក គ្រាប់បែកផ្សែង និងឡានទឹក។ អស់រយៈពេលពេញមួយថ្ងៃ និងឈានទៅដល់ពេលរាត្រី ក៏មានការប៉ះទង្គិចដ៏ច្របូកច្របល់ បានកើតឡើងជាច្រើនកន្លែងនៅរាជធានីភ្នំពេញដែលធ្វើឲ្យអ្នកធ្វើដំណើរ ប្រជាពលរដ្ឋ និងកម្មករធ្វើដំណើរមិនរួចជាប់ស្ទះនៅពាក់កណ្តាលផ្លូវ។ ក្នុងអំឡុងពេលការប៉ះទង្គិចគ្នានៅស្ពានអាកាសក្បាលថ្ល់ មានចម្ងាយប្រមាណ៥ គីឡូម៉ែត្រពីកន្លែងប៉ះទង្គិចមុនដំបូងនៅវិថីព្រះស៊ីសុវត្ថិនោះ កម្លាំងប្រដាប់អាវុធបានបាញ់គ្រាប់ពិត ដែលបានធ្វើឲ្យមនុស្សយ៉ាងហោចណាស់៩នាក់រងរបួសធ្ងន់ធ្ងរ ហើយធ្វើឲ្យលោក ម៉ៅ សុខចាន់ អាយុ២៩ឆ្នាំ ជាអ្នកឈរមើលហេតុការណ៍នោះ បាត់បង់ជីវិត ខណៈដែលខ្លួនធ្វើដំណើរពីផ្ទះទៅស៊ីឈ្នួលយាមតូបកាសែតឲ្យគេ។

ឧប្បត្តិហេតុបន្ទាប់គឺការបាញ់គ្រាប់កាំភ្លើងដោយកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាល ដែលបណ្តាលឲ្យប្រជាពលរដ្ឋស៊ីវិលម្នាក់ស្លាប់កាលពីខែវិច្ឆិកា ឆ្នាំ២០១៣។ ច្រើនខែក្រោយមក មានអំពើហិង្សាកើតឡើងជាច្រើនហូរហែដូចជា ការធ្វើកូដកម្មរបស់កម្មកររនៅរោងចក្រផលិតសម្លៀកបំពាក់ អេស.អិល ស្ថិតក្នុងខណ្ឌមានជ័យ ដែលកូដកម្មនោះបានបន្តរហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ខណៈពេលពីរបីម៉ោងក្រោយមកក៏មានភាពច្របូកច្របល់កើតឡើងរវាងអ្នកតវ៉ា និងកងកម្លាំងប្រដាប់អាវុធ។ ក្នុងអំឡុងពេលប៉ះទង្គិចគ្នានោះ កងកម្លាំងប្រដាប់អាវុធបានបំបែកក្រុមបាតុករដោយហិង្សា តាមរយៈការបាញ់គ្រាប់ពិត គ្រាប់ជំរ និងបាញ់គ្រាប់បែកផ្សែងបង្ហូរទឹកភ្នែក។ នៅក្នុងអំឡុងពេលប្រឈមគ្នានោះ ស្ត្រីលក់ដូរនៅលើចិញ្ចើមថ្ល់ម្នាក់អាយុ៤៩ឆ្នាំ ឈ្មោះ អេង សុខុម ដែលគ្រាន់តែឈរមើល មិនបានចូលរួមក្នុងការតវ៉ាផងនោះ ត្រូវបានកងកម្លាំងប្រដាប់អាវុធបាញ់ហើយបានស្លាប់នៅពេលបញ្ជូនមកដល់មន្ទីរពេទ្យ។[4] ជាសរុប អ្នកតវ៉ា៩នាក់បានរងរបួសដោយការបាញ់ប្រហាររបស់នគរបាល ក្នុងនោះមានម្នាក់បានពិការជាអចិន្ត្រៃយ៍រហូតមកដល់សព្វថ្ងៃ ហើយជាច្រើននាក់ផ្សេងទៀតត្រូវបានវាយដំនឹងដំបងយ៉ាងដំណាំពីសំណាក់នគរបាល។[5]

---

[4] ម.ស.ម.ក "ការប្រើកម្លាំងហួសហេតុលើការតវ៉ារបស់កម្មករ" (សលាកប័ត្រព័ត៌មាន) (ខែវិច្ឆិកា ឆ្នាំ២០១៣) អាចរកបានតាម៖ http://bit.ly/1cKfOu4។

[5] ដដែល ។

បាតុកម្មបានកើតឡើងកាន់តែច្រើនឡើងៗនៅចុង ឆ្នាំ២០១៣ នៅពេលកម្មករកាត់ដេរបន្តធ្វើកូដកម្ម នៅទាំងប្រទេសដោយស្នើឲ្យមានការដំឡើងប្រាក់ឈ្នួលអប្បបរមា។ ខណៈដែលឆ្នាំថ្មីឆ្នាំសកលមកដល់ ការបង្ក្រាបទៅលើសេរីភាពខាងការជួបប្រជុំ និងការតវ៉ានានាកើតឡើងកាន់តែខ្លាំងឡើងៗ។ នៅថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤ អង្គភាពឆ័ត្រយោងពិសេសលេខ ៩១១ បានបង្ក្រាបលើការតវ៉ាមួយរបស់កម្មកររោងចក្រ យ៉ាក ជីន ស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ ជាយរាជធានីភ្នំពេញ ដោយបានចាប់ខ្លួន និងវាយដំយ៉ាងហិង្សាទៅលើសកម្មជនសហជីពចំនួន ១០ នាក់ និងកម្មករកាត់ដេរជាច្រើននាក់ទៀត ព្រមទាំងព្រះសង្ឃចំនួន ៥ អង្គ។[6] ខណៈដែលព្រះសង្ឃទាំង ៥ អង្គត្រូវបានដោះលែងនៅយប់ដដែលនោះ អ្នកទាំង ១០ នាក់ផ្សេងទៀតនៅបន្តជាប់ឃុំខ្លួន ហើយត្រូវបានចោទប្រកាន់ពីបទហិង្សា និងបង្កការខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស។ ដោយសារមានកំហឹងចំពោះការចាប់ខ្លួនដោយហិង្សាដែលបានកើតឡើងនៅរោងចក្រ យ៉ាក ជីន នោះ កម្មករកាត់ដេរបានប្រមូលផ្តុំគ្នាពេលយប់នៅតាមដងផ្លូវ វេងស្រេង សួនឧស្សាហកម្មកាណាឌីយ៉ា។ បន្ទាប់ពីមានការប្រឈមមុខដាក់គ្នាមួយយប់ជាមួយនគរបាល នៅព្រឹកថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ កម្លាំងប្រដាប់អាវុធ បានបាញ់គ្រាប់កាំភ្លើងពិត ដោយមិនញញើតចូលទៅក្នុងហ្វូងបាតុករ ដែលបណ្តាលឲ្យមានមនុស្សយ៉ាងហោចណាស់ ៤ នាក់បានស្លាប់ហើយមនុស្សរាប់សិបនាក់ទៀតរងរបួស។[7] កងកម្លាំងប្រដាប់អាវុធ បានសម្លាប់កម្មករកាត់ដេរចំនួន ៤ នាក់រួមមាន យាន រិទ្ធី អាយុ ២៥ឆ្នាំ ផេង កុសល អាយុ ២៣ឆ្នាំ គឹម ផល្លាក អាយុ២៤ឆ្នាំ និង សម វ៉ាវី អាយុ ២៥ឆ្នាំ។[8] នៅថ្ងៃនោះ ដៃរមានមនុស្សចំនួន ១៣ នាក់ត្រូវបានអាជ្ញាធរចាប់ខ្លួន។ លើសពីនេះទៀត យុវជន ខឹម សុផាត អាយុ១៦ ឆ្នាំបានបាត់ខ្លួនចាប់តាំងពីពេលនោះមក។ យុវជនរូបនេះ ត្រូវបានគេឃើញចុងក្រោយ ខណៈពេលដេកនៅលើដីដោយមានឈាមហូរស្រោចខ្លួនដោយសារត្រូវគ្រាប់កាំភ្លើងបាញ់ចំដើមទ្រូង។ កន្លងមកពុំមានឮដំណឹងណាមួយស្តីពីទីតាំងរបស់យុវជនរូបនេះ ដែលផ្តល់ដោយអាជ្ញាធរនៅឡើយទេ រហូតមកដល់ពេលនេះ។

ការការពារលើសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន[9] គឺជាចំណុចសំខាន់នៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រប្រទេសកម្ពុជា (“រដ្ឋធម្មនុញ្ញ”)។ ការសម្លាប់តាមរយៈការប្រើកម្លាំងខុសច្បាប់ពីសំណាក់កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋត្រូវបានចាត់ទុកថាជាការសម្លាប់តាមតែអំពើចិត្ត។ ក្រមប្រតិបត្តិរបស់មន្ត្រីអនុវត្តច្បាប់ (“ក្រមសីលធម៌”) និងគោលការណ៍មូលដ្ឋានស្តីពីការប្រើកម្លាំង និងអាវុធរបស់មន្ត្រីអនុវត្តច្បាប់ (“គោលការណ៍មូលដ្ឋាន”) ដែលបានអនុម័តដោយអង្គការសហប្រជាជាតិ ផ្តល់ការ

---

[6] ម.ស.ម.ក “ការចាប់ខ្លួន និងការចោទប្រកាន់លើអ្នកការពារសិទ្ធិមនុស្ស គឺ លោក វ៉ន ពៅ ប្រធានសមាគមអាយឌ្ហា” (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1dMuwAD ។

[7] ម.ស.ម.ក “ថ្កោលទោសចំពោះការបង្ក្រាបដោយហិង្សារបស់រដ្ឋាភិបាលលើបញ្ហាសិទ្ធិមនុស្ស និងការធ្វើឲ្យអន់ថយដល់ស្ថានភាពលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា” (សេចក្តីថ្លែងការណ៍) (ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤) អាចរកបានតាមរយៈ:http://bit.ly/1csqRy5។

[8] លីកាដូ “បញ្ជីឈ្មោះអ្នកស្លាប់ និងបុរសបាត់ខ្លួន កាលពីបាតុកម្មថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤” អាចរកបានតាម៖ http://bit.ly/1kpFgxK។

[9] មាត្រា ៣ និងមាត្រា ៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (“ស.ស.ស.ម”) និងមាត្រា ៦ និងមាត្រា ៩ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”)។

ណែនាំទៅលើហេតុផលដែលអាចចាត់ថាជាការប្រើកម្លាំងត្រឹមត្រូវតាមច្បាប់ ឬមិនត្រឹមត្រូវតាមច្បាប់របស់កងកម្លាំងសន្តិសុខ។

យោងតាមគោលការណ៍មូលដ្ឋាន មុនពេលសម្រេចប្រើកងកម្លាំង និងអាវុធ វិធានការផ្តល់ដំណោះស្រាយអហិង្សាទាំងអស់ត្រូវតែប្រើឲ្យអស់លទ្ធភាពជាមុនសិន។ កងកម្លាំងត្រូវបានប្រើប្រាស់តែក្នុងករណីចាំបាច់បំផុតតែប៉ុណ្ណោះ ហើយត្រូវតែសមស្របទៅតាមគោលបំណងរបស់ច្បាប់ជានិច្ច។ អាវុធប្រើបានតែក្នុងកាលៈទេសៈពុំអាចទប់ស្កាត់បាន និងប្រើបានតែក្នុងករណីការពារខ្លួន ឬការពារអ្នកដទៃទប់ទល់ទៅនឹងការគំរាមសម្លាប់ ឬគ្រោះថ្នាក់ដែលបម្រុងនឹងកើតមានឡើង។ ករណីស្រដៀងគ្នានេះ ការប្រើកងកម្លាំង និងអាវុធដែលបង្កឲ្យមានការស្លាប់មនុស្សដោយចេតនានឹងត្រូវអនុញ្ញាតតែក្នុងកាលៈទេសៈដែលពុំអាចជៀសវាងបានប៉ុណ្ណោះក្នុងគោលបំណងដើម្បីការពារអាយុជីវិតមនុស្ស។[10]

ការប្រើកម្លាំងរបស់កងកម្លាំងប្រដាប់អាវុធនៅកម្ពុជា គឺពិតជាពុំត្រឹមត្រូវតាមច្បាប់ ហើយអាចចាត់ទុកថា ជាការប្រើកម្លាំងពុំសមាមាត្រ និងហួសហេតុ។ ហេតុដូច្នោះ កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលបានប្រព្រឹត្តអំពើមនុស្សឃាតតាមអំពើចិត្ត ហាក់ដូចជាធ្វើឲ្យមានការបាត់ខ្លួនដោយបង្ខំនូវអ្នកតវ៉ាម្នាក់ ដែលត្រូវតែទទួលខុសត្រូវចំពោះការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី។[11]

សិទ្ធិទទួលបានការពិត សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបានដំណោះស្រាយ

សិទ្ធិទទួលបានការពិត យុត្តិធម៌ និងដំណោះស្រាយសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្ស គឺពិតជាជាប់ពាក់ព័ន្ធ និងបង្កើតកាតព្វកិច្ចដល់រដ្ឋ ដើម្បីប្រឆាំងនឹងអំពើនិទណ្ឌភាព។ ការកំណត់ជាថ្មីនៃគោលការណ៍សម្រាប់ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព (“គោលការណ៍ថ្មី”) ចាប់តាំងពី ខែកុម្ភៈ ឆ្នាំ២០០៥[12] ដែលបានចែងនៅក្នុងគោលការណ៍ ១ ថា៖

> *“និទណ្ឌភាពកើតចេញពីការខកខានរបស់រដ្ឋក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការស៊ើបអង្កេតលើករណីរំលោភបំពាននានា ដើម្បីចាត់វិធានការសមស្របចំពោះជនដៃដល់ ជាពិសេស នៅជុំវិញបរិបទយុត្តិធម៌ ដោយធានាថាជនសង្ស័យដែលមានទោសព្រហ្មទណ្ឌទាំងនោះ ត្រូវបានចោទប្រកាន់កាត់ទោស និងផ្តន្ទាទោសដើម្បីផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពជូនដល់ជនរងគ្រោះ និងដើម្បីធានាថា ជនរងគ្រោះទទួលបានសំណងត្រឹមត្រូវចំពោះការរងរបួស និងដើម្បីធានាសិទ្ធិទទួលបានការពិតដែលមិនអាចដកហូតបានលើការរំលោភបំពាន និងចាត់វិធានការចាំបាច់នៅ*

---

[10] អង្គការសហប្រជាជាតិ គោលការណ៍មូលដ្ឋានស្តីពីការប្រើកម្លាំង និងអាវុធ ពីសំណាក់មន្ត្រីអនុវត្តច្បាប់ ថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩០ បទប្បញ្ញត្តិទូទៅ អាចរកបានតាម៖ http://bit.ly/1dtR5f7 ។

[11] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា២១ នៃ ក.អ.ស.ព.ន។

[12] ក្រុមប្រឹក្សាផ្នែកសេដ្ឋកិច្ច និងសង្គមរបស់ អ.ស.ប “ ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស៖ ការកំណត់ជាថ្មីពីគោលការណ៍សម្រាប់ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើនិទណ្ឌភាព” គណៈកម្មាធិការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស កិច្ចប្រជុំលើកទី៦១ ប្រការលេខ១៧ (ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៥) អាចរកបានតាម៖http://bit.ly/1hHxrQi។

ដំណាក់កាលដទៃទៀត ដើម្បីទប់ស្កាត់ការរំលោភបំពានដែលនឹងអាចកើតមានឡើងសារជាថ្មី" (មានបញ្ជាក់បន្ថែម)

សិទ្ធិទទួលបានការពិតគឺជាសិទ្ធិមិនអាចដកហូតបាន ហើយជាសិទ្ធិស្វយភាព។[13] គោលការណ៍ទី៤ នៃគោលការណ៍ថ្មីនេះ ចែងថា "ដោយមិនគិតពីនីតិវិធីច្បាប់ ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់មានសិទ្ធិដឹងពីការពិតចំពោះព្រឹត្តិការណ៍ដែលមានការរំលោភបំពានបានកើតឡើង រឿងរ៉ាវដែលមានមនុស្សស្លាប់ ឬបាត់ខ្លួន និងជោគវាសនារបស់ជនរងគ្រោះ។" ជាងនេះទៅទៀត មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចនៅខែធ្នូ ឆ្នាំ២០១៣ ស្តីពីសិទ្ធិទទួលបានការពិតដែលគួសបញ្ជាក់ជាថ្មីពីសារៈសំខាន់នៃការគោរព និងធានាសិទ្ធិទទួលបានការពិតក្នុងន័យដើម្បីចូលរួមចំណែកបញ្ចប់និទណ្ឌភាព និងដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស[14]។

សិទ្ធិទទួលបានការពិតគឺពាក់ព័ន្ធយ៉ាងស្និទ្ធទៅនឹងកាតព្វកិច្ចរបស់រដ្ឋ ក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពទៅក្នុងការរំលោភបំពានសិទ្ធិមនុស្សទាំងមូល។ គោលការណ៍ថ្មីនេះចែងពីសិទ្ធិទទួលបានយុត្តិធម៌របស់ជនរងគ្រោះ និងកាតព្វកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេត និងធានាថាជនដែលទទួលខុសត្រូវចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិត្រូវបានចោទប្រកាន់ កាត់ទោស និងផ្តន្ទាទោសត្រឹមត្រូវ។[15]សិទ្ធិទទួលបានយុត្តិធម៌រាប់បញ្ចូលទាំងសិទ្ធិទទួលបានដំណោះស្រាយតាមផ្លូវតុលាការផងដែរ។ គោលការណ៍របស់ អ.ស.ប ស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការកាត់ទោសក្រៅប្រព័ន្ធច្បាប់ ការកាត់ទោសតាមអំពើចិត្ត និងការកាត់ទោសរយៈពេលខ្លីក៏បានចែងផងដែរពីកាតព្វកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេតនូវរាល់ការកាត់ទោសតាមអំពើចិត្ត និងការកាត់ទោសរយៈពេលខ្លីទាំងអស់។ [16] បន្ថែមពីនេះ កតិកាសញ្ញាអន្តរជាតិសម្រាប់ការពារបុគ្គលគ្រប់រូបមិនឲ្យមានការបាត់ខ្លួនដោយបង្ខំ[17] ដែលកម្ពុជាបានទទួលស្គាល់នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ

---

[13] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស "ការសិក្សាលើសិទ្ធិទទួលបានការពិត" (របាយការណ៍) (ង/គន.៤/២០០៦/៩១) (ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៦) អាចរកបានតាម៖ http://bit.ly/OfPl2f។

[14] មហាសន្និបាតរបស់ អ.ស.ប "ដំណោះស្រាយបានអនុម័តដោយអង្គមហាសន្និបាតនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ៖ ៦៨/១៦៥ ស្តីពីសិទ្ធិទទួលបានការពិត" កិច្ចប្រជុំលើក ៦៨ របៀបវារៈទី៦៩ (ខ) ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤) អាចរកបានតាមរយៈ ៖ http://bit.ly/1dVzFaH។

[15] គោលការណ៍ថ្មី គោលការណ៍ទី១៩។

[16] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម "គោលការណ៍ស្តីពីការទប់ស្កាត់ និងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពលើការកាត់ទោសក្រៅប្រព័ន្ធច្បាប់ ការកាត់ទោសតាមអំពើចិត្ត និងការកាត់ទោសរយៈពេលខ្លី" (ដំណោះស្រាយ) លេខ ១៩៨៩/៦៥ (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ១៩៨៩) អាចរកបានតាម៖ http://bit.ly/1lUjSB3។

[17] ការបាត់ខ្លួនដោយបង្ខំ មានផ្តល់និយមន័យក្នុងមាត្រា ២ នៃ ICCPED គឺជា ៖ ការចាប់ខ្លួន ការឃុំខ្លួន ការកាត់បន្ថយ ឬការដកហូតនូវទម្រង់ផ្សេងៗនៃសេរីភាពពីសំណាក់ភ្នាក់ងាររដ្ឋាភិបាល ឬពីសំណាក់បុគ្គល ឬក្រុមរបស់បុគ្គល ដែលបំពេញការងារតាមច្បាប់អនុញ្ញាតក្រោមការគាំទ្រ ឬទទួលស្គាល់ពីរដ្ឋ បានធ្វើតាមការបដិសេធក្នុងការទទួលស្គាល់ ការដកហូតសេរីភាព ឬការលាក់បំបាំងនៃជោគវាសនា ឬទីសំចតរបស់ជនដែលបានបាត់ខ្លួននោះ ដែលដាក់បុគ្គលនោះឲ្យស្ថិតនៅក្រៅការការពារផ្នែកច្បាប់" អាចរកបាន៖ http://bit.ly/1lUkk2q។

២០១៣ ដែលកំណត់ភារកិច្ចរបស់រដ្ឋាភិបាលក្នុងការស៊ើបអង្កេតជុំវិញករណីបាត់ខ្លួនដោយបង្ខំតាមមាត្រា ៣ នៃកតិកាសញ្ញាអន្តរជាតិនេះ។[18]

សិទ្ធិទទួលបានដំណោះស្រាយ រួមជាមួយសិទ្ធិនានាដូចបានរៀបរាប់មកខាងលើ ក៏ដូចជាសិទ្ធិទទួលបានសំណង ត្រូវបានធានានៅក្នុងមាត្រា ៨ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សិទ្ធិទទួលបានដំណោះស្រាយរួមមាន៖ សិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិទទួលបានសំណងពីព្យសនកម្មដល់ជនរងគ្រោះ និងសិទ្ធិទទួលបានព័ត៌មានលម្អិតនៅជុំវិញអំពើហិង្សាដែលពួកគេបានពើបប្រទះ ព្រមទាំងយន្តការផ្តល់សំណង [19] ។ សំណងចំពោះករណីរំលោភបំពានទាំងនេះគួរតែធនល្មមទៅនឹងព្យសនកម្មដែលជនរងគ្រោះទទួលរង ហើយរាប់បញ្ចូលទាំងបដិទាន ការសងជំងឺចិត្ត នីតិសម្បទា ការពេញចិត្ត និងធានាពុំឲ្យមានការរំលោភបំពានកើតឡើងសារជាថ្មី។

បរាជ័យរបស់រដ្ឋាភិបាលក្នុងការប្រកាន់ខ្ជាប់ភាពឯកច្ឆរបស់ខ្លួន

បន្ទាប់ពីការប៉ះទង្គិច នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ រវាងកម្មករសហជីពក្រកាត់ដេរ អេស.អិល និងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាល អ្នកនាំពាក្យរបស់នគរបាលជាតិ លោក គាត ចាន់ថារិទ្ធ បានប្រាប់កាសែត*ភ្នំពេញប៉ុស្តិ៍* ថា គណៈកម្មការស៊ើបអង្កេតត្រូវបានបង្កើតឡើងដើម្បីកំណត់អត្តសញ្ញាណនគរបាលដែលបានប្រើប្រាស់កាំភ្លើង។ [20] ចាប់តាំងពីនោះមក គ្មានលទ្ធផលជុំវិញការស៊ើបអង្កេតនោះត្រូវបានអាជ្ញាធរចេញផ្សាយទេ។[21]

នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៤ លោកឧត្តមសេនីត្រីយ៍ ខេង ទីតូ បានមានប្រសាសន៍ថា ការស៊ើបអង្កេតណាមួយក្នុងករណីស្លាប់៣នាក់ កាលពីខែមករា ពុំមែនជាតួនាទីរបស់កងរាជអាវុធហត្ថទេ តែជាតួនាទីរបស់ "អ្នកញុះញង់" ដែលបានដឹកនាំការតវ៉ា[22] ហើយនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ រដ្ឋាភិបាលបានប្រកាសឲ្យបង្កើតគណៈកម្មការចំនួនពីរដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកឧត្តម ស ខេង ដើម្បីស៊ើបអង្កេតពីមូលហេតុបង្កឲ្យមានការខូចខាត "បាតុកម្មអនាធិបតេយ្យ" ហើយគណៈកម្មការទីពីរ ធ្វើការស៊ើបអង្កេតពីរបៀបដែលអំពើញុះញង់បានកើតឡើង។ [23] បីសប្តាហ៍ក្រោយមក មានការប្រកាសថាការស៊ើបអង្កេតត្រូវបានបញ្ចប់ ប៉ុន្តែ

---

[18]មាត្រា ៣ នៃ ICCPED។

[19] មហាសន្និបាតរបស់ អ.ស.ប "គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ" (ដំណោះស្រាយ) កិច្ចប្រជុំលើកទី៦០ ប្រការ ៧១ (ក) (ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦) អាចរកបានតាម៖http://bit.ly/OVlBZA។

[20] ហ្សែន រ៉ាវ៉ែល និង ម៉ម គុន្ធា "នគរបាលដែលបានបាញ់ប្រហារក្នុងករណីកូដកម្មត្រូវបានស៊ើបអង្កេត" កាសែត ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣) អាចរកបានតាម៖http://bit.ly/1i28U7t ។

[21] ម៉ែ ទិត្យថារ៉ា "ក្រុមសិទ្ធិមនុស្សរិះគន់លើការស៊ើបអង្កេតរបស់រដ្ឋាភិបាល" កាសែត*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/MKwBXI។

[22] ឃួន ណារឹម និង ខូលីន ម្យ៉ាន "គ្មានលទ្ធផលពីការស៊ើបអង្កេតក្នុងករណីបាញ់ប្រហារក្នុងការតវ៉ា" *ខេម បូឌាដេលី*អាចរកបានតាម៖ http://bit.ly/1dWztbk។

[23] ម៉ែ ទិត្យថារ៉ា ក្រុមសិទ្ធិមនុស្សរិះគន់លើការស៊ើបអង្កេតរបស់រដ្ឋាភិបាល" កាសែត*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/MKwBXI។

គ្មានលទ្ធផលផ្លូវការណាមួយត្រូវបានចេញផ្សាយនោះទេ។[24] នៅចុងខែមករា ឆ្នាំ២០១៤ មន្ត្រីចំនួន ៥ រូប ដែលពុំបានបញ្ចេញឈ្មោះត្រូវបានព្រះរាជអាជ្ញានៃសាលាដំបូងរាជធានីភ្នំពេញ សាកសួរពាក់ព័ន្ធទៅនឹងការប៉ះទង្គិចនោះ ប៉ុន្តែយោងតាមលោកឧត្តមសេនីត្រីយ៍ ខេង ទីតូ គ្មានមន្ត្រីរូបណាបានប្រឈមការចោទប្រកាន់នោះទេ ដោយហេតុថា ពួកគេបានធ្វើសកម្មភាពការពារខ្លួន។[25]

គណៈកម្មការបានបង្កើតឡើងដោយរដ្ឋាភិបាលពុំបានស៊ើបអង្កេតពីតួនាទីរបស់កងទ័ព និងនគរបាលក្នុងការប្រើកម្លាំងដ៏ហួសហេតុ ពុំសមាមាត្រ និងការបាញ់គ្រាប់ពិតលើអ្នកតវ៉ា ប៉ុន្តែបែរជាស៊ើបអង្កេតទៅលើអ្នកតវ៉ាទៅវិញ។ គណៈកម្មការនោះ ពុំឯករាជ្យ និងគ្មានតម្លាភាព ដោយហេតុថា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃគឺជាអ្នកដឹកនាំគណៈកម្មការដើម្បីស៊ើបអង្កេតក្រោមការបង្គាប់បញ្ជារបស់ខ្លួនហើយការរកឃើញនានាមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ។ គណៈកម្មការទាំងនោះបង្កើតឡើងពុំមានន័យអ្វីនោះទេ គឺគ្រាន់តែរម្ងាប់អារម្មណ៍របស់សហគមន៍អន្តរជាតិ។ លើសពីនេះទៅទៀត ការលើកឡើងរបស់រដ្ឋាភិបាលគ្រាន់តែពីភាពលម្អៀងរបស់ខ្លួនទៅខាងកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះ។

យោងតាមកាសែត *កោះសន្តិភាព* នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងភរិយាលោក គឺលោកជំទាវ ប៊ុន រ៉ានី បានផ្តល់រង្វាន់ដល់មន្ត្រីកងរាជអាវុធហត្ថចំនួន២៩នាក់ និងមន្ត្រីនគរបាលជាតិចំនួន២១៦ នូវទឹកប្រាក់ម្នាក់ប្រហែល ២០០ដុល្លាអាមេរិកក្នុងបុព្វហេតុ "ការពារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។"[26] អត្ថបទនោះស្រង់សម្តីថា *"[សម្តេចហ៊ុន សែន និង លោកជំទាវ ប៊ុន រ៉ានី] សរសើរគោលជំហរមុឺងម៉ាត់របស់កម្លាំងនគរបាល និងកម្លាំងកងរាជអាវុធហត្ថដែលខិតខំការពារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ខណៈដែលគណបក្សប្រឆាំងបានបង្កើតបរិយាកាសដើរញុះញង់បង្កឲ្យមានអំពើហិង្សា។"*[27] នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ដោយគូសបញ្ជាក់ថា ការដោះស្រាយបញ្ហានានានៅក្នុង ឆ្នាំ២០១៣ បានសម្រេចដោយជោគជ័យ។[28] នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានប្រកាសផងដែរថា នគរបាលប្រមាណ ៣,១០០ នាក់ នឹងទទួលបានប្រាក់ឧបត្ថម្ភចំនួន ១៧.៥០ ដុល្លាអាមេរិក ជាការថ្លែងអំណរគុណចំពោះការបង្ក្រាបលើការតវ៉ានានា។[29] បន្ថែមពីនេះ ក្នុងអំឡុងការត្រួតពិនិត្យជាសាកលតាមពេលកំណត់នាពេល

---

[24] មាស សុខដា "គ្មានដំណឹងសោះ ខណៈដែលការស៊ើបអង្កេតករណីបាញ់សម្លាប់នៅផ្លូវវ៉ៃង៉ស្រេងបានបញ្ចប់" កាសែត ភ្នំពេញ ប៉ុស្ត៍ (ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1dE2442 ។

[25] ប៊ុត រស្មីគង្គា និងដាញ៉ែល ប៉ាយ "មន្ត្រីត្រូវបានសាកសួរដោយតុលាការពីករណីបាញ់ប្រហារ" កាសែត ភ្នំពេញប៉ុស្ត៍ (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤) (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1cyH93f។

[26] ឃួន ណារឹម និងខូលីន ម្យ៉ាន "គ្មានលទ្ធផលពីការស៊ើបអង្កេតក្នុងករណីបាញ់ប្រហារក្នុងការតវ៉ា" *ខេម បូឌាដេលី* អាចរកបានតាម៖ http://bit.ly/1dWztbk។

[27] មានប្រភពដូចខាងលើ។

[28] មាស សុខដា " នាយករដ្ឋមន្ត្រី សារទេរចំពោះការចាត់វិធានការរបស់យោធាលើការតវ៉ា" កាសែត *ភ្នំពេញប៉ុស្ត៍* (ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1fDWXHF។

[29] មានប្រភពដូចខាងលើ។

ចុងក្រោយនេះរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ គណៈប្រតិភូកម្ពុជាបានទទួលយកអនុសាសន៍ របស់សាធារណៈរដ្ឋឆែក ចំពោះ"ការស៊ើបអង្កេតដោយមិនលម្អៀងទៅលើករណីប្រើកម្លាំងហួសហេតុប្រឆាំងលើអ្នកតវ៉ា និងករណីមានមនុស្សស្លាប់ក្នុងអំឡុងពេលបាតុកម្មនាពេលថ្មីៗនេះ។"[30] ដោយជំនួសពីការដែលត្រូវព្រះរាជអាជ្ញាសាកសួរ កងកម្លាំងប្រដាប់អាវុធបានទទួលនូវការកោតសរសើរចំពោះសកម្មភាពដែលនាំឲ្យអ្នកតវ៉ាត្រូវស្លាប់ និងបាត់ខ្លួនទៅវិញ។

នៅពេលទន្ទឹមគ្នានោះដែរ អ្នកតវ៉ាបានទទួលលទ្ធផលផ្សេងៗគ្នាដូចជាការប្រឈមនឹងការចាប់ខ្លួន ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងការឃាត់ខ្លួន។ មនុស្ស៦នាក់ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ទាក់ទិនទៅនឹងព្រឹត្តិការណ៍នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ នៅពេលដែលលោក ម៉ៅ សុខចាន់ ត្រូវបានបាញ់សម្លាប់ ប៉ុន្តែ យោងតាមអង្គការឃ្លាំមើលសិទ្ធិមនុស្ស (យូមែន រ៉ៃត៍ វ៉ច្ច)[31] មានតែបុរសម្នាក់ប៉ុណ្ណោះក្នុងចំណោមបុរសទាំង៦នាក់ ដែលជាអ្នកចូលរួមនៅក្នុងបាតុកម្មរបស់គណបក្សប្រឆាំង រីឯអ្នកផ្សេងទៀតគ្រាន់តែជាអ្នកនៅក្បែរនោះខណៈដែលខ្លួនធ្វើដំណើរទៅផ្ទះរបស់ខ្លួន។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ សាលាដំបូងរាជធានីភ្នំពេញបានរកឃើញពិរុទ្ធភាពជន៣នាក់ ក្នុងចំណោមបុរសទាំង៦នាក់នោះពីបទ "ហិង្សាដោយចេតនា និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយចេតនា។"[32] ជន នាក់ក្នុងចំណោមជនបីនាក់ដែលសាលាដំបូងចោទប្រកាន់ នៅពេលនេះត្រូវបានដោះលែងឲ្យមានសេរីភាព ដោយហេតុថាទោសនោះត្រូវបានព្យួរ។ ប៉ុន្តែ លោក ង្វៀង ធីដុក នឹងត្រូវអនុវត្តទោសរយៈពេល១ឆ្នាំ ផ្អែកលើហេតុផលថា រូបលោកបានសារភាពថា បានចោលដុំថ្មលើកម្លាំងនគរបាល បើទោះជា លោកប្រកាន់ជំហរថាការសារភាពរបស់លោកនេះធ្វើឡើងដោយសារការបង្ខិតបង្ខំ។[33] បុរសទាំងនេះត្រូវបានផ្តន្ទាទោសបើទោះជាមិនមានភស្តុតាងច្បាស់លាស់យ៉ាងណាក៏ដោយ។ ក្នុងអំឡុងពេលសវនាការមន្ត្រីនគរបាលចំនួន ៣០ រូប ដែលបានផ្តល់សក្ខីកម្ម ពុំបានបង្ហាញអត្តសញ្ញាណបុរសណាម្នាក់ក្នុងចំណោមបុរសទាំង ៦ នាក់នោះថាជាជនដៃដល់ក្នុងបទល្មើសព្រហ្មទណ្ឌនោះទេ[34]។

មនុស្ស ៣៨ នាក់ ត្រូវបានចាប់ខ្លួននៅថ្ងៃប៉ះទង្គិចគ្នារបស់កម្មកររោងចក្រ អេស.អិល កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ហើយមានបុរសពីរនាក់គឺ មាស ណុន អាយុ ១៥ឆ្នាំ និងឈ្មោះ វណ្ណ៉ វណ្ណៈ អាយុ១៩ឆ្នាំ

---

30 ក្រុមការងារលើការត្រួតពិនិត្យជាសកល និងទៀតទាត់ "របាយការណ៍ពង្រាងរបស់ក្រុមការងារលើការត្រួតពិនិត្យជាសកល និងទៀតទាត់" ក/គណៈកម្មការសិទ្ធិមនុស្ស/សង.៦/១៨/ល.៤ កិច្ចប្រជុំលើកទី១៨ (ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/O05R6X ។

31 អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា៖ ដោះលែងមនុស្ស៦នាក់ដែលត្រូវបានចាប់ខ្លួនដោយច្រឡំក្នុងអំឡុងចលាចល" (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1mLpED9។

32 អង្គការ លីកាដូ "សាលក្រមករណីក្បាលថ្នល់៖ បុរសម្នាក់ជាប់ពន្ធនាគារ រីឯអ្នកបាញ់នៅតែរួចខ្លួន" (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1dHX4fD។

33 ឃុត សុភ័ក្រចរិយា និង ស៊ាន ទីហាន " មិនអាចដាក់មុខ" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1bZBTKN។

34 ឃុត សុភ័ក្រចរិយា និង ស៊ាន ទីហាន " មិនអាចដាក់មុខ" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖ http://bit.ly/1bZBTKN។

ត្រូវបានចោទប្រកាន់នៅពេលបន្ទាប់ពីបទហិង្សា និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ មាស ណន ត្រូវបានដោះលែងឲ្យស្ថិតនៅក្រៅឃុំកាលពី ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៤ ខណៈដែល វណ្ណី វណ្ណៈ ស្ថិតនៅក្នុងការឃុំខ្លួន ដោយពន្យារពេលការជំនុំជម្រះ[35]។

មានមនុស្ស២៣នាក់ រួមទាំងមេដឹកនាំសហជីព និងសកម្មជនសិទ្ធិមនុស្សត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២ និងថ្ងៃទី៣ ខែមករា នៅខាងក្រៅរោងចក្រ យ៉ាក ជីន និងសួនឧស្សាហកម្មកាណាឌីយ៉ា។ ចាប់តាំងពីការចាប់ខ្លួនជនទាំងនោះមក មនុស្សទាំង ២៣ នាក់ត្រូវបានបដិសេធម្តងហើយម្តងទៀតនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ពួកគេត្រូវបានឃុំខ្លួនដោយអាជ្ញាធរអស់រយៈពេល៥ថ្ងៃ ដោយពុំអាចទាក់ទងជាមួយមេធាវីការពារក្តី ការថែទាំសុខភាព ឬមិនអនុញ្ញាតិឲ្យជួបក្រុមគ្រួសាររបស់ខ្លួន។ ជាចុងក្រោយ អាជ្ញាធរបានបង្ហាញព័ត៌មាននៅថ្ងៃទី៧ ខែមករា ថាអ្នកទាំង២៣ នោះកំពុងតែឃុំខ្លួននៅមណ្ឌលកែរប្រែ ម៣ ក្នុងខេត្តកំពង់ចាម ដោយធ្វើដំណើរអស់រយៈពេល ៦ម៉ោងពីភ្នំពេញ។ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ សាលាឧទ្ធរណ៍បានបដិសេធសំណើសុំនៅក្រៅឃុំរបស់បុរសទាំង ២១ នាក់ ខណៈដែលបុរស ២ នាក់ក្នុងចំណោមពួកគេត្រូវបានសាលាឧទ្ធរណ៍អនុញ្ញាតឲ្យស្ថិតនៅក្រៅឃុំក្នុងអំឡុងពេលសវនាការមួយកាលពីព្រឹក ថ្ងៃទី៧ ខែកុម្ភៈ ហើយត្រូវបានដោះលែងនៅថ្ងៃបន្ទាប់ ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។ ដីកាសម្រេចនេះ បានតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានបដិសេធសំណើសុំនៅក្រៅឃុំរបស់បុរសទាំង ២៣ នាក់នោះ ដោយផ្អែកលើហេតុផលបញ្ឈប់បទល្មើស ទប់ស្កាត់មិនឲ្យមានបទល្មើសថ្មី និងធានាថាជនជាប់ឃុំមានវត្តមាននៅពេលជំនុំជម្រះ។ សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍បដិសេធសំណើសុំនៅក្រៅឃុំត្រូវបានធ្វើឡើង បើទោះជាមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពសុខភាពរបស់អ្នកទាំងនោះក្តី។[36]

រដ្ឋាភិបាលខកខានក្នុងការការពារសិទ្ធិទទួលបានការពិត យុត្តិធម៌ និងដំណោះស្រាយរបស់ជនរងគ្រោះ ដោយបដិសេធការស៊ើបអង្កេតដោយឯករាជ្យ និងតម្លាភាពករណីប្រើកម្លាំងហួសហេតុពីសំណាក់កងកម្លាំងប្រដាប់អាវុធរដ្ឋាភិបាល ដែលនាំទៅរកការកាត់ទោសតាមអំពើចិត្ត ការបាត់ខ្លួន និងរបួសស្នាម។ ផ្ទុយមកវិញ រដ្ឋាភិបាលបានកាត់ទោស និងចោទប្រកាន់អ្នកតវ៉ា ហើយបន្តបដិសេធនូវសិទ្ធិសេរីភាពខាងការជួបប្រជុំរបស់ប្រជាពលរដ្ឋកម្ពុជា។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សមាជិកកងកម្លាំងប្រដាប់អាវុធត្រូវបានឡើងតំណែង និងកោតសរសើរ ខណៈដែលក្រុមគ្រួសារនានារបស់ជនរងគ្រោះកំពុងតែសោកសង្រេងដោយសារលទ្ធផលអំពើហិង្សានោះ។ ករណីនេះ កើតឡើងជាញឹកញាប់ណាស់ ហើយជាការបង្ហាញពីវប្បធម៌ទិណ្ឌភាពដែលរាលដាលនៅប្រទេសកម្ពុជា។ ការមិនស៊ើបអង្កេត និងការ

---

35 លីាង សារិទ្ធិ "អ្នកតវ៉ារោងចក្រ អេសអិលចំនួន១៥ ត្រូវបានដោះលែង" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1fB1Hhs ។

36 ម.ស.ម.ក "ការបដិសេធសំណើសុំនៅក្រៅឃុំចំពោះអ្នកការពារសិទ្ធិមនុស្ស២១នាក់ និងអ្នកតវ៉ានៅថ្ងៃនេះ បង្ហាញពីស្ថានភាពសិទ្ធិមនុស្សកាន់តែធ្ងន់ធ្ងរនៅកម្ពុជា" (សេចក្តីថ្លែងការណ៍) (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤) អាចរកបានតាម៖http://bit.ly/1eqzmoH។

មិនកាត់ទោសជនល្មើសក្នុងការរំលោភបំពានសិទ្ធិមនុស្ស រដ្ឋាភិបាលកំពុងផ្ញើរសារថា ឥរិយាបថបែបនេះអាចកើតឡើងជាថ្មីម្តងទៀត។

យុត្តិធម៌ត្រូវតែមានសម្រាប់អ្នកតវ៉ា និងប្រជាពលរដ្ឋស្លូតត្រង់ដែលបាត់បង់ជីវិត អ្នកបាត់ខ្លួន និងអ្នករងរបួសចាប់តាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយសារករណីប្រើកម្លាំងហួសហេតុពីសំណាក់កងកម្លាំងប្រដាប់អាវុធរដ្ឋាភិបាល។ ដូច្នេះ ម.ស.ម.ក សូមផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលដូចខាងក្រោម៖

- ធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយហ្មត់ចត់ និងដោយប្រសិទ្ធភាព តាមរយៈស្ថាប័នឯករាជ្យ និងឥតលម្អៀងក្នុងករណីប្រើកម្លាំងហួសហេតុ ការប្រើអាវុធពីសំណាក់មន្ត្រីអនុវត្តច្បាប់
- ចេញផ្សាយនូវរាល់លទ្ធផលនៃការស៊ើបអង្កេតទាំងអស់ដល់សាធារណៈជនទូទៅ ជាពិសេស ជនរងគ្រោះ និងក្រុមគ្រួសារជនរងគ្រោះ
- នាំយកជនទាំងឡាយណាដែលបានកំណត់ថាជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្ស មកផ្តន្ទាទោស នៅចំពោះមុខសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងឥតលម្អៀង
- ជានានូវសិទ្ធិទទួលបានដំណោះស្រាយ និងសំណងរបស់ជនរងគ្រោះ
- ដោះលែងឲ្យបុរសទាំង ២១ នាក់ដែលត្រូវអាជ្ញាធរចាប់ខ្លួននៅថ្ងៃទី២ និង ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ឲ្យនៅក្រៅឃុំជាបន្ទាន់
- គោរពសិទ្ធិសេរីភាពខាងការជួបប្រជុំរបស់បុគ្គល ដោយជានាថា បម្រាមលើការជួបប្រជុំនានាត្រូវបានឈប់អនុវត្ត និងត្រូវបានដកចេញជាផ្លូវការ
- ជានាថា មន្ត្រីអនុវត្តច្បាប់ទាំងអស់ត្រូវបានផ្តល់ការបណ្តុះបណ្តាលពាក់ព័ន្ធជំនាញនានា និងត្រូវសាកល្បងជំនាញដោយអនុលោមតាមបទដ្ឋានត្រឹមត្រូវក្នុងការប្រើប្រាស់កម្លាំង
- ជាក់ពង្រាយមន្ត្រីយោធាបានតែនៅក្នុងបញ្ហាសន្តិសុខជាតិធ្ងន់ធ្ងរប៉ុណ្ណោះ ហើយត្រូវបញ្ឈប់កងសន្តិសុខនៅតាមខណ្ឌ ស្រុក ក្នុងការបំបែកការជួបប្រជុំ និង
- ជានាថា មន្ត្រីអនុវត្តច្បាប់ប្រើប្រាស់អាវុធ ដែលមិនអាចបង្កឲ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្សក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១៧៦៥៥ ៥៩២ឬអ៊ីម៉ែល៖ ramanasorn@cchrcambodia.org **ឬ កញ្ញា ជូលីយ៉ែត រ៊ូសែលឡត តាមរយៈទូរសព្ទ៖** + ៨៥៥(០)១៥ ៣៥ ០៦ ២០ **ឬ អ៊ីម៉ែល៖** julietterousselot@cchrcambodia.org ។